**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងពាណិជ្ជកម្ម**

លេខ ១៣៩ ព.ណ.ជ.ល.ប្រក

# ប្រកាស

## ស្តីពីការកែសម្រួល បំពេញបន្ថែមបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៤ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងអនុរដ្ឋលេខាធិការ នៃក្រសួង និងរដ្ឋលេខាធិការដ្ឋាន នៃរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ១២៧ អនក្រ.បក ចុះថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ មាត្រា៤ និងបន្ថែមមាត្រា៨ ស្ទួន នៃអនុក្រឹតលេខ ៥៩ អនក្រ.បក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការដំឡើងនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ឲ្យទៅជាអគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហរ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ចំណុះក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ១៖** កំណត់បែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មដូចខាងក្រោម ៖

១- ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ជាប្រធានស្ថាប័ន ទទួលខុសត្រូវរួមការងារក្នុងក្រសួង ជាពិសេសដឹកនាំត្រួតពិនិត្យ និងតាមដានការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ របស់រាជរដ្ឋាភិបាល លើរាល់ចំណុចដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ច របស់ក្រសួងពាណិជ្ជកម្ម និងដោយឡែកដឹកនាំគ្រប់គ្រង៖

- នាយកដ្ឋានបុគ្គលិក នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋាននាំចេញ-នាំចូល នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល) ក្រុមហ៊ុនហ្វ្រីនត្រេដ និងតំណាងពាណិជ្ជកម្មក្រៅប្រទេស
- ពិនិត្យតាមដានរាល់ការងារពាក់ព័ន្ធជាមួយក្រសួងមហាផ្ទៃ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ប្រធានក្រុមការងារផ្នែកផលិតកម្មកែច្នៃសម្រាប់នាំចេញ និងកិច្ចសម្រួលពាណិជ្ជកម្ម ។
  - ឯកឧត្តម **ស៊ុន ដារ៉ាចន្ទ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មៈ ទទួលភារកិច្ចជានាយកខុទ្ទកាល័យជួយការងាររដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងសម្របសម្រួលការងារក្នុងក្រសួងពាណិជ្ជកម្ម
  - ឯកឧត្តម **ប៉ាច ហេងសារា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មៈ ទទួលភារកិច្ចជួយការងារ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រគល់ជូន
  - ឯកឧត្តម **ម៉ក់ ឧសភា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មៈ ទទួលភារកិច្ចជួយការងារ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រគល់ជូន និងសម្របសម្រួលការងារជាមួយ អគ្គនាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញនីហរ័ណ អាហារ័ណ និងបង្ក្រាបការក្លែងបន្លំ (កាំកុងត្រូល)។

២- ឯកឧត្តម **គឹម ស៊ីថន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្មទទួលបន្ទុកសម្របសម្រួលការងារទូទៅក្នុងក្រសួង

  - ឯកឧត្តម **រាជ រ៉ា** ឯកឧត្តម **សុខ សុភ័ក្ត្រ** ឯកឧត្តម **ប៉ាច ហេងសារា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មខេត្តកំពង់ស្ពឺ មន្ទីរពាណិជ្ជកម្មខេត្តព្រះសីហនុ មន្ទីរពាណិជ្ជកម្មខេត្តកោះកុង និង មន្ទីរពាណិជ្ជកម្មខេត្តកែប
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងការពារជាតិ ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងមុខងារសាធារណៈ និង រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- ក្រុមការងារផ្នែកថាមពល-ហេដ្ឋារចនាសម្ព័ន្ធ និងដឹកជញ្ជូន។

៣- ឯកឧត្តម **ឱក ប៊ុន** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចដឹកនាំៈ

  - ឯកឧត្តម **ចាន់ រ៉ាស៊ី** ឯកឧត្តម **ម៉ក់ ឧសភា** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានអាមេរិក មន្ទីរពាណិជ្ជកម្មខេត្តកំពង់ចាម មន្ទីរពាណិជ្ជកម្មខេត្តត្បូងឃ្មុំ មន្ទីរពាណិជ្ជកម្មខេត្តក្រចេះ មន្ទីរពាណិជ្ជកម្មខេត្តស្ទឹងត្រែង និងមន្ទីរពាណិជ្ជកម្មខេត្តរតនគិរី
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអាមេរិក
- ពិនិត្យតាមដានផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងធនាគារជាតិកម្ពុជា
- ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ។

៤- ឯកឧត្តម **ម៉ៅ ថូរ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចដឹកនាំៈ

- លោកជំទាវ **ស្ុ ស្រីម៉ិច** ឯកឧត្តម **សុខ សុភ័ក្ត្រ** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក នាយកដ្ឋាននីតិកម្ម នាយកដ្ឋានផ្តល់ព័ត៌មាន និងផ្ទៀងផ្ទាត់ច្បាប់ នាយកដ្ឋានអភិវឌ្ឍន៍វិស័យឯកជន នាយកដ្ឋានគោលនយោបាយពាណិជ្ជកម្ម មន្ទីរពាណិជ្ជកម្មខេត្តព្រៃវែង មន្ទីរពាណិជ្ជកម្មខេត្តស្វាយរៀង និងមន្ទីរពាណិជ្ជកម្ម ខេត្តមណ្ឌលគិរី
- ពិនិត្យ និងសម្រេចចុះហត្ថលេខាលើវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញ (C/O) នាំចេញទៅអាស៊ីប៉ាស៊ីហ្វិក
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងធនធានទឹក និងឧតុនិយម ASEAN/ASEM/ACMECS/ESCAP ការងារសហប្រតិបត្តិការតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ការងារសហប្រតិបត្តិការតំបន់មរតកកម្ពុជា-ឡាវ-ថៃ ក្រុមប្រឹក្សាកសិកម្ម និងអភិវឌ្ឍន៍ អង្គការពាណិជ្ជកម្មអន្តរជាតិ និងសភាពាណិជ្ជកម្មកម្ពុជា
- ក្រុមការងារផ្នែកកសិកម្ម កសិ-ឧស្សាហកម្ម សហព័ន្ធស្រូវអង្ករកម្ពុជា
- ក្រុមការងារផ្នែកស្រូវ-អង្ករ។

៥- ឯកឧត្តម **ឈួន ដារ៉ា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចដឹកនាំៈ

- ឯកឧត្តម **សំ សិរីរតន៍** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានកិច្ចការពិពរណ៍ នាយកដ្ឋានអភិវឌ្ឍន៍ទីផ្សារ តំណាងពាណិជ្ជកម្មប្រចាំតំបន់សេដ្ឋកិច្ចពិសេស មន្ទីរពាណិជ្ជកម្មខេត្តកណ្តាល មន្ទីរពាណិជ្ជកម្ម ខេត្តតាកែវ និងមន្ទីរពាណិជ្ជកម្មខេត្តកំពត
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍
- ក្រុមការងារផ្នែកទេសចរណ៍។

៦- លោកជំទាវ **តឹករ៉េត កំរេខ** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចដឹកនាំៈ

- ឯកឧត្តម **ម៉េង សុធី** ឯកឧត្តម **ឃឹម សិរីវឌ្ឍន៍** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុ នាយកដ្ឋានរដ្ឋបាល នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ មន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ មន្ទីរពាណិជ្ជកម្មខេត្តកំពង់ឆ្នាំង មន្ទីរពាណិជ្ជកម្មខេត្តពោធិសាត់ មន្ទីរពាណិជ្ជកម្មខេត្តបាត់ដំបង មន្ទីរពាណិជ្ជកម្មខេត្តប៉ៃលិន និងមន្ទីរពាណិជ្ជកម្មខេត្តបន្ទាយមានជ័យ
- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយ ក្រសួងកិច្ចការនារី ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងរ៉ែ និងថាមពល ក្រសួងសុខាភិបាល និងក្រសួងធម្មការ និងសាសនា
- ក្រុមការងារផ្នែកសេវាធនាគារ និងហិរញ្ញវត្ថុ។

៧- ឯកឧត្តម **អ៊ុក ប្រជា** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ទទួលភារកិច្ចដឹកនាំៈ

- លោកជំទាវ **ចម និម្មល** ឯកឧត្តម **គីម សុខុន** អនុរដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម

- នាយកដ្ឋានកម្មសិទ្ធិបញ្ញា នាយកដ្ឋានផែនការ ស្ថិតិ និងព័ត៌មានពាណិជ្ជកម្ម វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវ
- មន្ទីរពាណិជ្ជកម្មខេត្តកំពង់ធំ មន្ទីរពាណិជ្ជកម្មខេត្តព្រះវិហារ មន្ទីរពាណិជ្ជកម្មខេត្តសៀមរាប និងមន្ទីរពាណិជ្ជកម្មខេត្តឧត្តរមានជ័យ

- ពិនិត្យផ្តល់យោបល់រាល់ការងារពាក់ព័ន្ធជាមួយក្រសួងឧស្សាហកម្ម និងសិប្បកម្ម ក្រសួងផែនការ ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ ក្រសួងព័ត៌មាន ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្រុមប្រឹក្សាជាតិកម្មសិទ្ធិបញ្ញា និងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- ក្រុមការងារផ្នែកកម្មន្តសាល និងសហគ្រាសធុនតូចមធ្យម
- ក្រុមការងារផ្នែកនីតិកម្ម ពន្ធដារ និងអភិបាលកិច្ច។

**ប្រការ២៖** អំពីភារកិច្ច និងសិទ្ធអំណាច៖

១- រដ្ឋលេខាធិការទទួលដឹកនាំ គ្រប់គ្រង តាមចង្កោមការងារទទួលបន្ទុកដែលបានប្រគល់ជូន និងផ្តល់យោបល់ជូនរដ្ឋមន្ត្រីពិនិត្យ សម្រេចលើរាល់សំណើដែលមានការពាក់ព័ន្ធ។

២- រដ្ឋលេខាធិការអាចប្រគល់សិទ្ធិពិនិត្យ និងសម្រេចជូនអនុរដ្ឋលេខាធិការ នូវការងារដែលស្ថិតនៅក្នុងចង្កោមការងាររបស់ខ្លួន។

**ប្រការ៣៖** អំពីរបបប្រជុំ៖

**ក-ប្រជុំសប្តាហ៍៖** នៅរៀងរាល់ព្រឹកថ្ងៃពុធ នឹងមានការប្រជុំក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានការចូលរួមពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករងកាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្វ្រីនត្រេដ ប្រធាននាយកដ្ឋាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានីភ្នំពេញ ប្រធានមន្ទីរពាណិជ្ជកម្មខេត្តកណ្តាល ដើម្បីស្តាប់របាយការណ៍ ពិភាក្សាដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

**ខ-ប្រជុំខែ៖** នៅរៀងរាល់ព្រឹកថ្ងៃពុធ សប្តាហ៍ចុងក្រោយនៃខែ នឹងមានការប្រជុំក្រោមការដឹកនាំ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ដែលមានការចូលរួមពីរដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយក អគ្គនាយករង អគ្គាធិការ អគ្គាធិការរង អគ្គនាយក អគ្គនាយករង កាំកុងត្រូល អគ្គនាយកក្រុមហ៊ុនហ្វ្រីនត្រេដ ប្រធាន អនុប្រធាននាយកដ្ឋាន និងប្រធាន អនុប្រធានអង្គភាពចំណុះក្រសួង ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី ខេត្ត ដើម្បីស្តាប់របាយការណ៍ ពិភាក្សា និងដោះស្រាយការងាររួម និងកែលម្អចំណុចខ្វះខាត។

**គ-ប្រជុំថ្នាក់អគ្គនាយកដ្ឋាន៖** នៅរៀងរាល់ខែនីមួយៗ អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកាំកុងត្រូល ក្រុមហ៊ុនហ្វ្រីនត្រេដ ត្រូវរៀបចំឲ្យមានការប្រជុំប្រចាំខែ ដើម្បីបូកសរុបអំពីសកម្មភាព និងលទ្ធផលការងារប្រចាំខែ លើកវិធានការដោះស្រាយ និងកំណត់ទិសដៅ ការងារដែលត្រូវធ្វើបន្ត។

**ឃ-ប្រជុំថ្នាក់នាយកដ្ឋាន៖** នៅរៀងរាល់ពីរសប្តាហ៍ម្តង នាយកដ្ឋានត្រូវរៀបចំ ឲ្យមានការប្រជុំផ្ទៃក្នុង នាយកដ្ឋានរបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់អង្គភាព។

**ង-ប្រជុំថ្នាក់មន្ទីរពាណិជ្ជកម្ម៖** នៅរៀងរាល់ខែនីមួយៗ មន្ទីរត្រូវរៀបចំឲ្យមានការប្រជុំផ្ទៃក្នុងមន្ទីររបស់ខ្លួននីមួយៗ ដើម្បីតាមដានការងាររបស់មន្ទីរ។

អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន អគ្គនាយកដ្ឋានកាំកុងត្រូល នាយកដ្ឋាន និងមន្ទីរពាណិជ្ជកម្ម ត្រូវធ្វើរបាយការណ៍អំពីលទ្ធផលនៃការប្រជុំតាមការកំណត់ខាងលើជូនរដ្ឋមន្ត្រី និងថ្នាក់ដឹកនាំក្រសួងដែលមានការពាក់ព័ន្ធជ្រាប និងផ្តល់ការណែនាំ។

**ប្រការ៤៖** បែងចែកការទទួលខុសត្រូវជំនួសនៅពេលអវត្តមានថ្នាក់ដឹកនាំណាម្នាក់ ដើម្បីធានាល្បឿនសេវារដ្ឋបាល និងធានាបន្តនិរន្តភាពគ្រប់គ្រង ដូចខាងក្រោម៖

១- ការងាររបស់ ឯកឧត្តម **ភឹម ស៊ីថន** ត្រូវជំនួសដោយ ឯកឧត្តម **ឱក ម៉ុខ**
២- ការងាររបស់ ឯកឧត្តម **ឱក ម៉ុខ** ត្រូវជំនួសដោយ ឯកឧត្តម **ម៉ៅ ថូរ៉ា**
៣- ការងាររបស់ ឯកឧត្តម **ម៉ៅ ថូរ៉ា** ត្រូវជំនួសដោយ ឯកឧត្តម **ឈួន ដារ៉ា**
៤- ការងាររបស់ ឯកឧត្តម **ឈួន ដារ៉ា** ត្រូវជំនួសដោយ លោកជំទាវ **តឹករ៉េត កំរេខ**
៥- ការងាររបស់ លោកជំទាវ **តឹករ៉េត កំរេខ** ត្រូវជំនួសដោយ ឯកឧត្តម **អ៊ុក ប្រជា**
៦- ការងាររបស់ ឯកឧត្តម **អ៊ុក ប្រជា** ត្រូវជំនួសដោយ ឯកឧត្តម **ភឹម ស៊ីថន**។

**ប្រការ៥៖** រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ត្រូវទទួលភារកិច្ចបន្ថែមជាក់ស្តែង ក្រៅពីភារកិច្ចដែលបានប្រគល់ជូនរួចតាមការប្រគល់របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម។

**ប្រការ៦៖** ប្រកាសលេខ ៣៤៣ ព.ណ.ខកល.ប្រក ចុះថ្ងៃទី១១ ខែតុលា ឆ្នាំ២០១៦ ស្តីពីការបែងចែកភារកិច្ចរបស់ថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្ម ត្រូវទុកជានិរាករណ៍។

**ប្រការ៧៖** នាយកខុទ្ទកាល័យ ឯកឧត្តម លោកជំទាវ ដែលមានឈ្មោះក្នុងប្រការ១ និង ប្រការ៤ អគ្គនាយក អគ្គាធិការ ប្រធាននាយកដ្ឋាន ប្រធានមន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត និងប្រធានអង្គភាពក្រោមឱវាទក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។៚

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែមិថុនា ឆ្នាំ២០១៧

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ប៉ាន សូរស័ក្តិ**

**ចម្លងជូន៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- អង្គភាពចំណុះក្រសួងពាណិជ្ជកម្ម
- សាលារាជធានី-ខេត្ត
- មន្ទីរពាណិជ្ជកម្មរាជធានី-ខេត្ត
- ដូចប្រការ ៧ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ